# វេទនាគ្រោះព្រោះវិស័យឯកជន

( លំនាំបទ ផាមួង កទា )

និពន្ធនិងច្រៀងដោយកម្មកររោងចក្រ

១- ឱផែនដីខ្មែរធ្លាប់តែស្រស់ថ្លា តែពេលនេះណាប្រែអាប់រស្មី

ឯកជនកាន់កាប់គ្មាននៅសល់អ្វី សេវាកម្មក៏ថ្លៃតើឱ្យរស់ម្តេចបាន?

បន្ទរ សេវាកម្មក៏ថ្លៃឱ្យរស់ម្តេចបាន? ។

២- មន្ទីរពេទ្យទឹកភ្លើង ហើយនិងផ្លូវថ្នល់ ឥឡូវរដ្ឋផ្តល់ឱ្យគេអស់ហើយ

តំលៃគេឡើងគ្មានឈប់ឈរឡើយ វិស័យឯកជនអើយទុកឱ្យយើងរស់ផង

បន្ទរ ឱឯកជនអើយទុកឱ្យយើងរស់ផង ។

៣- អ្នកផ្តល់ជំនួយបានភ្ជាប់ចំណង ថែមបំណុលផងចងរដ្ឋយើងហើយ

នេះមិនមែនកម្មត្រូវទទួលឡើយ ប្រទេសច្រើនហើយដែលរងទុក្ខវេទនា

បន្ទរ ប្រទេសច្រើនហើយរងទុក្ខវេទនា ។

៤- ប្រទេសក្រីក្រដែលធ្លាក់រណ្តៅ ក្នុងពិភពខ្មៅមើលទៅថាល្អ

តែតាមការពិតជាច្រវាក់ទាក់ក យើងត្រូវក្រោកឈរប្តូរនឹងសេរីភាព

បន្ទរ យើងត្រូវក្រោកឈរប្តូរនឹងសេរីភាព ។